៣-ឯកឧត្តម នូវ កានុន អគ្គលេខាធិការ មានឋានៈស្មើនឹងរដ្ឋលេខាធិការ

៤-ឯកឧត្តម សូត្រ សយ អគ្គលេខាធិការរង មានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ

៥-ឯកឧត្តម មួង សារ៉េត អគ្គលេខាធិការរង មានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ

៦-ឯកឧត្តម អ៊ូ គឹមសន អគ្គលេខាធិការរង មានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ

មាត្រា ២ .- ប្រធានឬ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធជាសមាជិកដែលនឹងត្រូវប្រកាសតែងតាំងដោយអនុក្រឹត្យ ដោយយោងតាមសំណើរបស់ប្រធាន ។

មាត្រា ៣ .- រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅប៉េកាំង ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨

ព្រះហស្តលេខា

នរោត្តម សីហនុ

=======

# II- រាជរដ្ឋាភិបាល

## ១ អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៧៩ អនក្រ-បក

### ស្តីពីការកែសំរួលរចនាសម្ព័ន្ធសមាសភាព និងតួនាទីភារកិច្ច របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ

***

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៥៦ អនក្រ-បក ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

-យោងតាមសំណើរបស់...

## សំរេច

## ជំពូកទី ១

## អំពីរចនាសម្ព័ន្ធ និងសមាសភាពនៃក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ ហៅកាត់ថា " កកជ ឬ CARD "

**មាត្រា ១ .-** សមាសភាពក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទត្រូវបានកែសំរួលដូចតទៅ :

| | |
|---|---|
| -នាយករដ្ឋមន្ត្រី | ប្រធាន |
| -ឥស្សរជនម្នាក់រូប មានឋានៈស្មើរដ្ឋមន្ត្រី | អនុប្រធាន |
| -រដ្ឋមន្ត្រី ឬតំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| -រដ្ឋមន្ត្រី ឬតំណាងក្រសួងផែនការ | សមាជិក |
| -រដ្ឋមន្ត្រី ឬតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| -រដ្ឋមន្ត្រី ឬតំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| -រដ្ឋមន្ត្រី ឬតំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| -រដ្ឋមន្ត្រី ឬតំណាងក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| -រដ្ឋមន្ត្រី ឬតំណាងក្រសួងបរិស្ថាន | សមាជិក |
| -រដ្ឋមន្ត្រី ឬតំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| -រដ្ឋមន្ត្រី ឬតំណាងក្រសួងផែនការ | សមាជិក |
| -រដ្ឋមន្ត្រី ឬតំណាងក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| -អគ្គទេសាភិបាលធនាគារជាតិ ឬតំណាង | សមាជិក |
| -ប្រធាន ធនាគារជនបទ | សមាជិក |
| -ប្រធាន មូលនិធិកាត់បន្ថយភាពក្រីក្រ | សមាជិក |
| -អគ្គលេខាធិការមូលនិធិសង្គម | សមាជិក |
| -អគ្គលេខាធិការក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | សមាជិក |

**មាត្រា ២ .-** បង្កើតអគ្គលេខាធិការដ្ឋាននៃ "កកជ" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការម្នាក់រូប និងមានអគ្គលេខាធិការរងមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

អគ្គលេខាធិការដ្ឋាននៃ កកជ មានផ្នែកជំនាញចំនួន ៦ ដោយមានមន្ត្រី ឯកទេសបំរើការ ៖

-ផ្នែក រដ្ឋបាល

-ផ្នែក បុគ្គលិក រួមមាន : ពិធីសារ សំភារៈ ហ្វឹកហ្វឺន និងធនធានមនុស្ស ។ល។

-ផ្នែក គណនី

-ផ្នែក អភិវឌ្ឍន៍ជនបទ

-ផ្នែក អាជីវកម្មព្រៃឈើ និងជលផល

-ធនធានទឹក (បរិក្ខារងារស្រោចស្រព)

មាត្រា ៣ .- អគ្គលេខាធិការ មានឋានៈស្មើ រដ្ឋលេខាធិការ ។ អគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ ។ ផ្នែកនិមួយៗ មានឋានៈស្មើនាយកដ្ឋាន ហើយដឹកនាំដោយ ប្រធានម្នាក់ ។

មាត្រា ៤ .- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ "កកជ" មានគណៈកម្មាធិការប្រតិបត្តិមួយ សំរាប់ដឹកនាំការងារប្រចាំថ្ងៃ ។

គណៈកម្មាធិការប្រតិបត្តិនៃ "កកជ" រួមមានសមាសភាពដូចតទៅ ៖

១-ប្រធាន "កកជ"

២-អនុប្រធាន "កកជ"

៣-អគ្គលេខាធិការ "កកជ"

៤-អគ្គលេខាធិការរង "កកជ"

ជំពូកទី ២

អំពីរចនាសម្ព័ន្ធ និង ភារកិច្ចរបស់ " កកជ ឬ CARD "

មាត្រា ៥ .- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ មានតួនាទីជាគណៈបញ្ញាការ សេនាធិការមួយ ជំនួយការអោយរាជរដ្ឋាភិបាល ក្នុងវិស័យស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយសហការគ្នាយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេសជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍កម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងធនធានទឹក និងឧតុនិយម ដើម្បីអនុវត្តអោយស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និងមានប្រសិទ្ធភាព ព្រមទាំងមានសិទ្ធិសំរេចអំពី អធ្យាក្រឹត្យ សំភារៈ ធន និងការងារផ្សេងៗទៀត ដែលផ្តល់អោយសំរេចភារកិច្ច ដែលមានចែងក្នុងមាត្រា៦ ។

មាត្រា ៦ .- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មានភារកិច្ចដូចខាងក្រោម ៖

-ទទួលបន្ទុកតាក់តែងតាមដាន ពិនិត្យលើគោលនយោបាយការអនុវត្តន៍ នូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងកម្មវិធីជាតិ នីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ចំពោះកិច្ចការស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ សំដៅប្រែក្លាយវិស័យកសិកម្ម ដែលមានបែបធ្វើ ដើម្បីផ្គត់ផ្គង់ខ្លួនឯងអោយទៅជាការផលិត ដើម្បីនាំចេញព្រមទាំងបន្ថយជាជំហានៗ នូវគំលាតឆ្ងាយ រវាងជនបទ និងទីក្រុង ។

-កំណត់កត្តាគន្លឹះទាំងឡាយ ដែលបំរើអោយការស្តារនិងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។

-កំណត់អាទិភាព និងកម្មវិធីនយោបាយ ក្នុងការស្តារនិងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ អោយសមស្របតាមគោលនយោបាយនៃរាជរដ្ឋាភិបាល ។

-ធានានិងសម្របសម្រួលការចូលរួមយ៉ាងសកម្មពីប្រជារាស្ត្រ ជាពិសេសក្រុមសហគមន៍ សហគមន៍ជនបទ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ជាមួយក្រសួង-ស្ថាប័នខេត្ត-ក្រុង ដើម្បីបង្កើនភាពសហប្រតិបត្តិការ និងភាពជាដៃគូ ក្នុងការស្តារនិងអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ដើម្បីធានាផលិតកម្ម និងអាជីវកម្ម ដោយនិរន្តរភាព និងធានាសន្តិសុខស្បៀង កាត់បន្ថយភាពក្រីក្រនៅជនបទ ។

-ពិនិត្យតាមដានការងារ ដោះស្រាយរាល់សំណើដែលបានស្នើសុំពីក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធនឹងការស្តារនិងអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ។ រាយការណ៍ និងសុំយោបល់រាជរដ្ឋាភិបាល លើបញ្ហាសំខាន់ៗ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៣

## ដំណើរការប្រព្រឹត្តិទៅរបស់ " គកជ ឬ CARD "

**មាត្រា ៧ .-** ប្រធាន " កកជ " មានតួនាទី និងភារកិច្ចដូចតទៅ :

-ទទួលខុសត្រូវលើការងាររបស់ "កកជ"

-ធ្វើជាអធិបតីភាពក្នុងអង្គប្រជុំរបស់ "កកជ" និងអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ "កកជ"

-ដឹកនាំពិភាក្សា និងប្រកាសបើកបិទសម័យ របស់អង្គប្រជុំពេញអង្គ "កកជ" និងអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិរបស់ "កកជ" ។

-កោះប្រជុំសាមញ្ញ ឬ ក្នុងករណីចាំបាច់ប្រជុំវិសាមញ្ញនៃអង្គប្រជុំ "កកជ" និង អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ "កកជ"

**មាត្រា ៨ .-** អនុប្រធាន " កកជ " មានតួនាទី និងភារកិច្ចដូចតទៅ :

-ទទួលខុសត្រូវជាទូទៅលើការងារ "កកជ" ក្នុងករណីប្រធានអវត្តមាន

-ទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ "កកជ"

-ធ្វើជាអធិបតីនៃអង្គប្រជុំ "កកជ" និងអង្គប្រជុំ គណៈកម្មាធិការប្រតិបត្តិ "កកជ" និងចុះហត្ថលេខាលើកំណត់ហេតុ និងសេចក្តីជូនដំណឹង នៃអង្គប្រជុំរបស់ "កកជ" ។

-ទទួលបន្ទុកការងារសម្របសម្រួលអន្តរក្រសួងរវាង "កកជ" ជាមួយក្រសួង-ស្ថាប័ន នៃរាជរដ្ឋាភិបាល ។

-ទទួលបន្ទុកទំនាក់ទំនងជាមួយភាគីបរទេស ដែលពាក់ព័ន្ធក្នុងការងារស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។

**មាត្រា ៩ .-** អគ្គលេខាធិការ មានតួនាទី និងភារកិច្ចដូចតទៅ :

-ទទួលបន្ទុកចាត់ចែងគ្រប់គ្រងការងាររបស់ អគ្គលេខាធិការដ្ឋាននៃ "កកជ" ។

-រៀបចំកម្មវិធីរបស់ "កកជ" និងរៀបចំរបៀបវារៈ និងសំណើរឯកសារផ្សេងៗ សំរាប់អង្គប្រជុំរបស់ "កកជ" និងអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ "កកជ" ។

-រៀបចំកំណត់ហេតុ សេចក្តីជូនដំណឹងអង្គប្រជុំ "កកជ" និងអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិ "កកជ" ដើម្បីដាក់ជូនអនុប្រធាន "កកជ" ចុះហត្ថលេខា ។

-រៀបចំរបាយការណ៍ "កកជ" ប្រចាំត្រីមាស ប្រចាំឆមាស ឬប្រចាំ ឆ្នាំ ។

-រៀបចំប្រកាសព័ត៌មាន របស់ "កកជ" ។

-ចូលរួមប្រជុំ "កកជ" និងអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិ "កកជ"

-បំពេញការងារផ្សេងៗទៀតដែលប្រធាន និង អនុប្រធាន "កកជ" ប្រគល់អោយ ។

មាត្រា ១០ .- អគ្គលេខាធិការរងនីមួយៗ បំពេញកិច្ចការតាមភារកិច្ច ដែលអគ្គលេខាធិការប្រគល់អោយ ។

មាត្រា ១១ .- សមាជិក "កកជ" មានតួនាទី និងភារកិច្ចដូចតទៅ :

-ចូលរួមប្រជុំសាមញ្ញ និងវិសាមញ្ញនៃអង្គប្រជុំរបស់ "កកជ" ដើម្បីពិនិត្យសំរេចរាល់សំណើរបស់ស្ថាប័នដែលពាក់ព័ន្ធដល់ការស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ

-សមាជិក ដែលជាប្រធានស្ថាប័នមានសមត្ថកិច្ច ពាក់ព័ន្ធនឹងការស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានភារកិច្ចលើកកម្មវិធីនយោបាយ របាយការណ៍ វិធានការ សំណើផ្សេងៗមក "កកជ" ដើម្បីពិនិត្យសំរេច ។

-ពិនិត្យ សំរេចលើរបាយការណ៍របស់ "កកជ" ប្រចាំត្រីមាស ប្រចាំឆមាស ឬ ប្រចាំឆ្នាំ ។

មាត្រា ១២ .- "កកជ" ត្រូវកោះប្រជុំសាមញ្ញយ៉ាងយូរ បីខែម្តង ។

មាត្រា ១៣ .- គណៈកម្មាធិការប្រតិបត្តិនៃ "កកជ" ត្រូវកោះប្រជុំសាមញ្ញ ពីរសប្តាហ៍ម្តងយ៉ាង ។

មាត្រា ១៤ .- "កកជ" មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬតំណាងស្ថាប័ន ឬមន្ត្រីជំនាញតាមការចាំបាច់ ដើម្បីចូលរួមប្រជុំ "កកជ" ឬប្រជុំគណៈកម្មាធិការប្រតិបត្តិ "កកជ "។

មាត្រា ១៥ .- អនុប្រធាន "កកជ" និងអគ្គលេខាធិការ "កកជ" មានសិទ្ធិចូលរួមប្រជុំពេញអង្គ នៃគណៈរដ្ឋមន្ត្រី តាមការអញ្ជើញរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ១៦ .- រាល់សកម្មភាពរដ្ឋបាល ថវិកាចំណាយ របស់ "កកជ" ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ របស់មន្ត្រីរាជការ ជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ១៧ .- ក្នុងករណីចាំបាច់ប្រធាន "កកជ អាចនឹងកោះប្រជុំវិសាមញ្ញរបស់ "កកជ" និងអង្គប្រជុំវិសាមញ្ញនៃគណៈកម្មាធិការប្រតិបត្តិនៃ "កកជ" ។

មាត្រា ១៨ .- ការប្រព្រឹត្តិទៅនៃអង្គប្រជុំរបស់ "កកជ" អង្គប្រជុំគណៈកម្មាធិការប្រតិបត្តិ ការរៀបចំ និងការប្រព្រឹត្តិទៅនៃអគ្គលេខាធិការដ្ឋាន "កកជ" ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ "កកជ" ។

## ជំពូកទី ៤

## អវសានបញ្ញត្តិ

មាត្រា ១៩ .- " កកជ " ប្រើត្រាទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២០ .- រាល់អនុក្រឹត្យ និងសេចក្តីសម្រេចពីមុន ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា២១ .- "គកជ"និងរាល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

======

## អនុក្រឹត្យ លេខ ៨០ អនក្រ-បក

### ស្តីពីការផ្ទេរអតីតរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា និងការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ និងឯកសាររបស់អធិការកិច្ចរាជរដ្ឋាភិបាល អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច

*****

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-តាមសំណូមពរនៃកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៨

### សំរេច

មាត្រា ១ .- ត្រូវបានផ្ទេរអតីតរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា រួមទាំងធនធានមនុស្ស និងធនធានថវិកា និងក្របខ័ណ្ឌមន្ត្រីរាជការទាំងអស់អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច ។

មាត្រា ២ .- អតីតរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ដែលមានចែងក្នុងមាត្រា១ខាងលើ ត្រូវរៀបចំធ្វើជាទីស្តីការក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច ។

មាត្រា ៣ .- ត្រូវបានផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ និងឯកសារទាំងអស់របស់អតីតអធិការកិច្ចរាជរដ្ឋាភិបាលនៅទីស្តីការគណៈរដ្ឋមន្ត្រី អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច ។